**ប្រកាសព័ត៌មាន**–ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៦

**ទីក្រុងសម្រាប់កុមារ**–អបអរទិវាកុមារអន្តរជាតិនៅក្នុងតំបន់ដែលមានប្រជាពលរដ្ឋក្រីក្រក្នុងរាជធានីភ្នំពេញ

អង្គការសមាគមធាងត្នោតជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក រួមសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍នៃសាធារណៈរដ្ឋឆែកដែលមានអង្គការភីពភលអ៊ីននីត (ភីន) នឹងប្រារព្ធទិវា "**ទីក្រុងសម្រាប់កុមារ**" សម្រាប់កុមារ និងមាតាបិតារបស់ពួកគេនៅក្នុងភូមិក សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ព្រឹត្តិការណ៍នេះនឹងត្រូវប្រារព្ធនៅ**ថ្ងៃពុធ ទី០១ ខែមិថុនា ឆ្នាំ២០១៦ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១១:០០ ព្រឹក** ខាងមុខវិហារធំឥស្លាមគីឡូលេខ០៩ ដែលស្ថិតនៅក្នុងភូមិ៣ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

អង្គការសមាគមធាងត្នោត និងអង្គការភីពផលអ៊ីននីត (ភីន)នឹងរៀបចំព្រឹត្តិការណ៍ដែលមានរយៈ ពេលកន្លះថ្ងៃសម្រាប់កុមារដែលមានចំនួនជាងមួយរយនាក់ រួមជាមួយនិងមាតាបិតារបស់ពួកគេដែលរស់នៅក្នុងភូមិក ដែលជាសហគមន៍ក្រីក្រមួយនៅក្នុងសង្កាត់ច្រាំងចំរេះទី២ រាជធានីភ្នំពេញ។ យោងតាមរបាយការណ៍របស់អង្គការសមាគមធាងត្នោត ចេញផ្សាយនៅក្នុងឆ្នាំ២០១៤ (ការអង្កេតអំពីរាជធានីភ្នំពេញ) កុមារ នៅក្នុងសហគមន៍ ៣៤០ទីតាំងដែលស្ថិតនៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ គឺពួកគេរស់នៅក្នុងស្ថានភាពលំបាក ដូចជាការ ទទួលបានគុណភាពទឹកមិនល្អក្នុងការប្រើប្រាស់ ឬសហគមន៍ខ្លះគ្មានទឹកស្អាតសម្រាប់ប្រើប្រាស់, ការប្រឈមអនាម័យមិនស្អាត កាកសំណល់ និងភ្លើងអគ្គិសនីមិនគ្រប់គ្រាន់ជាដើម។ យោងតាមការស្រាវជ្រាវដែលបោះពុម្ពដោយអង្គការភីន កាលពីឆ្នាំកន្លងទៅបានឱ្យដឹងថារាល់កុមារទីបីដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញគឺគ្មាន អាហារហូបចុកគ្រប់គ្រាន់ មានភាព ស្លេកស្លាំង ខ្សោយកម្លាំង និងរៀនមិនសូវពូកែ។ ព្រឹត្តិការណ៍នេះលើកទឹកចិត្តដល់កុមារទាំងអស់ដើម្បីឱ្យ ពួកគេបានគិតគូអំពីបរិស្ថានរស់នៅក្នុងទីក្រុងតាមរយៈការពិភាក្សាអំពី "ទីក្រុងដ៏ស្រស់សោភា"របស់ពួកគេដែលពួកគេនឹងបង្កើតបានតាមរយៈការគូរគំនូរនេះ។

> *លោក អ៊ី សារ៉ុម នាយកប្រតិបត្តិអង្គការសមាគមធាងត្នោតបានមានប្រសាសន៍ថា "ព្រឹត្តិការណ៍នេះគឺជាឱកាសមួយសម្រាប់កុមារក្នុងការ នាំមកនូវបំណងប្រាថ្នារបស់ពួកគេសម្រាប់លំនៅដ្ឋាន របស់ពួកគេអស់មួយជីវិតតាមរយៈសកម្មភាពសប្បាយៗ។ វាក៏មានន័យថា កុមារទាំងនេះនឹង បានដឹងតាំងពីខ្លួននៅក្មេងថា ពួកគេអាចមានសម្លេងក្នុងការអភិវឌ្ឍទីក្រុង។"*

នៅក្នុងឆ្នាំ២០១៦ អង្គការភីន, អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង, និងវិទ្យាស្ថានបើកទូលាយបានចាប់ផ្តើមជំហានទី២នៃកិច្ចសហប្រតិបត្តិការ "ទីក្រុងសម្រាប់យើងទាំងអស់គ្នា របស់គម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស ដែល ផ្តល់មូលនិធិដោយគណៈប្រតិភូសហគមន៍អឺរ៉ុបនៅក្នុងប្រទេសកម្ពុជា និងទីភ្នាក់ងារអភិវឌ្ឍន៍នៃសាធារណៈរដ្ឋឆែក។ គម្រោងដែលមានរយៈពេលបីឆ្នាំនេះផ្សព្វផ្សាយអំពីវិធីសាស្ត្រទាក់ទងនឹងសិទ្ធិក្នុងការចូលរួមអភិវឌ្ឍន៍ទីក្រុង។ បច្ចុប្បន្ន គម្រោងនេះកំពុងអនុវត្តនៅក្នុងភូមិក ក្នុងសង្កាត់ច្រាំងចំរេះទី២ ដែលជាសហគមន៍កំពុងប្រឈមមុខនឹងការបណ្តេញចេញ។ នៅឆ្នាំខាងមុខនេះ គម្រោងនេះនឹងត្រូវធ្វើនៅក្នុងតំបន់បឹងទំពុនផងដែរ។ គម្រោងនេះធ្វើការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានដើម្បីផ្តល់ដល់ឱ្យប្រជាពលរដ្ឋនូវការវាយតម្លៃទាក់ទងនឹង ការកាន់កាប់ដីធ្លីស្របច្បាប់ និងរៀបចំ

ផែនការទីក្រុងថ្មីៗដើម្បីកែលម្អសហគមន៍នៅនឹងកន្លែងក្នុងគោលបំណងធ្វើឱ្យការប្រើប្រាស់ដីធ្លីកាន់តែមាន ប្រសិទ្ធភាព ជៀសវាងការតាំងលំនៅថ្មីដោយមិនមានការព្រមព្រៀងគ្នា។

*លោក អ៊ី សារ៉ុម នាយកប្រតិបត្តិអង្គការសមាគមជាងត្នោតបានមានប្រសាសន៍បន្ថែមថា"ទិវាកុមារអន្តរជាតិគឺជាឱកាសមួយដើម្បីឆ្លុះបញ្ចាំងអំពីសិទ្ធិ និងសុខុមាលភាពរបស់កុមារ ជាពិសេសអ្នកដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ។ ស្ថានភាពរស់នៅក្នុងលក្ខណៈលំបាក និងការប្រឈមក្នុងការបណ្តេញចេញបានធ្វើឱ្យមានការគម្រាមកំហែងដល់សិទ្ធិទាំងអស់នោះ។ គម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្សគឺជាជំហានដ៏មានសារៈសំខាន់មួយដើម្បីឈានទៅទទួលបានសិទ្ធិសម្រាប់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញដោយផ្តោតលើការអភិវឌ្ឍនៅក្នុងទីក្រុង។*

បន្ថែមទៅនឹងការងារទូទៅដែលបានអនុវត្ត នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង គម្រោង"ទីក្រុងសម្រាប់យើងទាំងអស់គ្នាដែលជាគម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស ក៏រៀបចំឱ្យមានការចូលរួមពីនិស្សិតនៅក្នុងរាជធានីភ្នំពេញ តាមរយៈវគ្គបណ្តុះបណ្តាលស្តីពី "គម្រោងរៀបចំផែនការទីក្រុង"។ វគ្គបណ្តុះបណ្តាលនេះរួមបញ្ចូលនូវសិក្ខាសាលា និងបទបង្ហាញនានា អំពីការធ្វើផែនការដីធ្លី បញ្ហាប្រឈមនឹងហានិភ័យ, គម្រោងរៀបចំដីធ្លី និងសិទ្ធិមនុស្ស, យែនឌ័រ និងការធ្វើផែនការលម្អទីក្រុង។ល។ ដើម្បីជួយដល់អ្នកដែលរៀបចំផែនការទីក្រុងនាពេលអនាគត ពិចារណាអំពីសារៈសំខាន់,អំពីវិធីសាស្រ្តដែលផ្តោតលើសិទ្ធិក្នុងការអភិវឌ្ឍទីក្រុងក្នុងរាជធានីភ្នំពេញ។ អង្គការភីន និងអង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រ ក្នុងទីក្រុង នឹងរៀបចំវាយតម្លៃផងដែរដើម្បីកំណត់អត្តសញ្ញាណ តំបន់ដែលងាយរងគ្រោះបំផុត និងពង្រឹងសមត្ថភាពសមាជិកនៅក្នុងសហគមន៍ក្នុងការទប់ទល់និង គ្រោះមហន្តរាយទាំងនោះ និងដាក់រចេញវិធានការកាត់បន្ថយសមស្របនានា ។

## សម្រាប់ព័ត៌មានបន្ថែមសូមមេត្តាទាក់ទង៖

**លោកសៅកុសល** ប្រធានកម្មវិធីបច្ចេកទេស របស់អង្គការសមាគមជាងត្នោត ០១៧ ៥៥៥ ៨៨៧ **(ផ្នែកភាសាខ្មែរ និងអង់គ្លេស)**
**លោក SASIN Piotr**, នាយកប្រចាំប្រទេស របស់អង្គការភីពភលអ៊ីននីត ( ភីន ) ០១១ ៦៧៦ ៣៣១ **(ផ្នែកភាសាអង់គ្លេស)**